# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រតិភូក្រុមហ៊ុនរោងចក្រមកពីចិន



នៅព្រឹកថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបប្រតិភូក្រុមហ៊ុនចិនមួយក្រុម រួមមាន ក្រុមហ៊ុន **Zigong Chuan Li Co,Ltd** ក្រុមហ៊ុន **Jia Hai Trading Company** និងក្រុមហ៊ុន **Sichoun Quingyuan Environment Engineering Co,Ltd** ដែលដឹកនាំដោយលោក **Shi Jian Guo** អនុប្រធានប្រតិបត្តិក្រុមហ៊ុន **Zigong Chuan Li Co,Ltd** ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ទាក់ទង និងគម្រោងវិនិយោគផ្នែករោងចក្រផលិតគ្រឿងបន្លាស់សម្រាប់ម៉ាស៊ីនរថយន្ត ។



មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងបានលើកឡើងពីលក្ខណៈអំណោយផលនិងសក្តានុពលនៃប្រទេសកម្ពុជា ទាំងផ្នែកនយោបាយ និងសេដ្ឋកិច្ច ។ ក្នុងនោះកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យម៧% ក្នុងរយៈប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលចាត់ទុកថាមានកំណើនខ្ពស់ជាងគេក្នុងតំបន់អាស៊ាន ។ ជាមួយគ្នានេះចំណុចពិសេសដែលកម្ពុជាមាន គឺកម្ពុជា ទទួលភាពអនុគ្រោះពាណិជ្ជកម្មពីបណ្តាប្រទេសអភិវឌ្ឍន៍ និងប្រទេសដៃគូជាច្រើនលើពិភពលោក ដោយសារកម្ពុជាជាប្រទេសអភិវឌ្ឍន៍តិចតួច ជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO និងជាសមាជិកនៃប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា ASEAN ដែលអនុញ្ញាតឱ្យទំនិញដែលនាំចេញពីកម្ពុជាទទួលបាន ការរួចពន្ធ និងមិនជាប់កូតានាំចេញ នូវមុខទំនិញក្រោមបន្ទាត់ពន្ធគយប្រមាណ៩៧% ។ ក្នុងនោះប្រទេសចិន ក៏ជាប្រទេសដែលបានផ្តល់ភាពអនុគ្រោះពាណិជ្ជកម្មដល់កម្ពុជាផងដែរ ។ ទាក់ទងនិងគម្រោងវិនិយោគផ្នែកផលិតគ្រឿងបន្លាស់រថយន្ត ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ សាទរស្របពេលដែលទីផ្សាររថយន្តនៅកម្ពុជាកំពុងមានការរីកចម្រើន និងប្រកួតប្រជែង ។ ចំពោះគម្រោងបង្កើតរោងចក្រផលិតគ្រឿងបន្លាស់ម៉ាស៊ីនរថយន្ត ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្នើឱ្យប្រតិភូក្រុមហ៊ុនចិន ចាប់អារម្មណ៍បោះទីតាំង នៅតំបន់សេដ្ឋកិច្ចពិសេស ដែលកម្ពុជាបានបង្កើតជាច្រើន ទាំងនៅរាជធានីភ្នំពេញ និងនៅតាមបណ្តាតំបន់ព្រំដែន ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានណែនាំ និងផ្តល់អាទិភាព នៅតំបន់សេដ្ឋកិច្ចពិសេសចំនួនពីរ គឺៈតំបន់សេដ្ឋកិច្ចពិសេស ខេត្តព្រះសីហនុ និងខេត្តស្វាយរៀង ដែលងាយស្រួលផលិតនាំចេញទៅកាន់ទីផ្សារប្រទេសថៃ និងវៀតណាម ក៏ដូចជា ប្រទេសមួយចំនួនទៀត ក្នុងតំបន់ និងក្រៅតំបន់ ។ ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ក៏បានលើកឡើងពីលំហូរដោយសេរី នូវមុខទំនិញ សេវាកំលាំងពលកម្ម និងមូលធន ជាដើម នៅពេលដែលរដ្ឋនៃសមាជិកអាស៊ាន នឹងបង្កើតបានជាសហគមន៍សេដ្ឋកិច្ចអាស៊ានមួយនៅចុងឆ្នាំ២០១៥ ។ ដូច្នេះ ជាឱកាសល្អសម្រាប់អ្នកផលិតចែកចាយ ពីព្រោះទំនិញធ្វើចរាចរណ៍ពីប្រទេសមួយ ទៅមួយដោយសេរី មិនជាប់ពន្ធ ដូចជាពីខេត្តមួយទៅខេត្តមួយ នៃប្រទេសមួយផងដែរ ។

ក្នុងដំណាក់កាលដល់ការសម្រេចចិត្តដាក់ទុនវិនិយោគនៅកម្ពុជា ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានណែនាំឱ្យប្រតិភូក្រុមហ៊ុនចិន ដាក់ពាក្យវិនិយោគ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) និងមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ហើយនៅពេលនោះក្រុមហ៊ុននឹងទទួលបានអត្ថប្រយោជន៍ជាច្រើនទៀតតាមច្បាប់វិនិយោគរបស់កម្ពុជា ដូចជា :ការលើកពន្ធលើប្រាក់ចំណេញ–ការរួចពន្ធការនាំចូលសំភារៈសំណង់បម្រើឱ្យការកសាងរោងចក្រ–មានសិទ្ធដាក់ដើមទុន ១០០% និងមិនកំហិតការផ្ទេរប្រាក់ចំណេញ ទៅក្រៅប្រទេសជាដើម ។

